PONLOK CHOMNES

ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា

# សេចក្តីសង្ខេបរបកគំហើញនៃការវាយតម្លៃ ស្តីពី វិស័យស្រាវជ្រាវនៅកម្ពុជា ២០១៩


**បណ្ឌិត ប៉ក់ គឹមជឿន**
**ប្រធានក្រុមអ្នកប្រឹក្សាស្រាវជ្រាវ**

**បណ្ឌិត** Arnaldo Pellini
**អ្នកប្រឹក្សាស្រាវជ្រាវ**

**អ្នកស្រី** Inala Fathimath
**អ្នកប្រឹក្សាស្រាវជ្រាវផ្នែកសមភាពយេនឌ័រ និងសង្គមបរិយាប័ន្ន**



Australian Aid

Australian Government
Department of Foreign Affairs and Trade

The Asia Foundation

# សេចក្តីសង្ខេបរបកគំហើញនៃការវាយតម្លៃស្តីពី<br>វិស័យស្រាវជ្រាវនៅកម្ពុជា

ដោយ៖ បណ្ឌិត ប៉ក់ គឹមជឿន បណ្ឌិត Arnaldo Pellini និងអ្នកស្រី Inala Fathimath

## ១. សេចក្តីផ្តើម គោលបំណង និងវិធីសាស្ត្រនៃការសិក្សា

នៅខែ ឧសភា ឆ្នាំ ២០១៩ អង្គការមូលនិធិអាស៊ី និងក្រសួងការបរទេស និងពាណិជ្ជកម្ម របស់រដ្ឋាភិបាលអូស្ត្រាលី ប្រចាំនៅប្រទេសកម្ពុជា បានផ្តល់ការងារឱ្យក្រុមជំនាញការ ចំនួន ៣ រូប ដើម្បីធ្វើការសិក្សាលើ វិស័យស្រាវជ្រាវខាងគោលនយោបាយនៅកម្ពុជា សម្រាប់ប្រើជាមូលដ្ឋានក្នុងកម្មវិធីពន្លកចំណេះ កម្មវិធីទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា។

របាយការណ៍សង្ខេបនេះ បង្ហាញនូវការរកឃើញពីការសិក្សា ដែលបានធ្វើឡើង កាលពីខែ កក្កដា និង ខែ សីហា ឆ្នាំ ២០១៩ ដោយការសិក្សានេះ មានគោលបំណងធំៗ ចំនួន ៣ គឺ៖

- ពិនិត្យមើលឡើងវិញនូវបញ្ហាអភិវឌ្ឍន៍ក្នុងប្រទេស ដែលកំពុងតែកើតមានឡើង និងកំណត់ពីវិស័យអាទិភាពនានា ឱ្យស្របគ្នាទៅនឹងគោលការណ៍សមភាពយេនឌ័រ និងបរិយាប័ន្នសង្គម (GESI) ។
- កំណត់ពីវិស័យស្រាវជ្រាវ និងធ្វើការពិចារណាដោយហ្មត់ចត់ ចំពោះអង្គការដែលរៀបចំបង្កើតការស្រាវជ្រាវ និងកស្តុតាង ដែលអាចជះឥទ្ធិពលដោយផ្ទាល់ ឬ ដោយប្រយោល ដល់ដំណើរការរៀបចំបង្កើតគោលនយោបាយ នៅក្នុងវិស័យអាទិភាពចំនួន ៣។
- ពិនិត្យមើលឡើងវិញនូវសមភាពយេនឌ័រ និងបរិយាប័ន្នសង្គម (GESI) នៅក្នុងរបៀបវារៈអភិវឌ្ឍន៍ក្នុងប្រទេស និងនៅក្នុងវិស័យស្រាវជ្រាវ ឱ្យបានកាន់តែទូលំទូលាយ ។

នៅក្នុងការសិក្សានេះ យើងបានយកនិយមន័យនៃពាក្យថា ប្រព័ន្ធស្រាវជ្រាវមកប្រើ ដែលវារៀបចំបង្កើតឡើង ដោយការផ្តួចផ្តើមលើវិស័យស្រាវជ្រាវនៅក្នុងប្រទេសឥណ្ឌូនេស៊ី (AusAID ២០១២)[1] "ដែលមានន័យថា ជាធាតុផ្សំក្នុងស្ថាប័ន (institutional landscape) របស់ក្រសួង ស្ថាប័ន វិស័យឯកជន និងអង្គការសង្គមស៊ីវិល ដែលបានផ្តល់លទ្ធផលនៃការស្រាវជ្រាវ និងការវិភាគនានា ដើម្បីចូលរួមចំណែកគាំទ្រ ដល់ការរៀបចំគោលនយោបាយសាធារណៈ"។ ដោយសារវិស័យស្រាវជ្រាវ មានលក្ខណៈជាប្រព័ន្ធបែបនេះ ទើបវិស័យនេះដើរតួនៅក្នុងគ្រប់ផ្នែកនៃវិស័យគោលនយោបាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាតុផ្សំសំខាន់ៗ នៃប្រព័ន្ធនេះរួមមាន៖

- **ការស្រាវជ្រាវ ដែលរៀបចំ**ដោយបណ្តាអង្គការនានា (ជាចំណុចផ្តោតចម្បងសម្រាប់ការសិក្សានេះ)
- អ្នករៀបចំគោលនយោបាយ និងមន្ត្រីរាជការស៊ីវិល ដែល**មានតម្រូវការ និងប្រើប្រាស់លទ្ធផល និងទិន្នន័យ**គ្រប់ប្រភេទ ដែលបានមកពីការស្រាវជ្រាវ ដើម្បីប្រើសម្រាប់ការជជែកពិភាក្សា និងការធ្វើសេចក្តីសម្រេច លើគោលនយោបាយ។

[1] AusAID (២០១២) ឯកសាររៀបចំការផ្តួចផ្តើមខាងវិស័យស្រាវជ្រាវ ទីក្រុងចាកាតា ប្រទេសឥណ្ឌូនេស៊ី

- អង្គការ និងបុគ្គលទាំងឡាយ ក្នុងនាមជា **អន្តរការី** ដែលបានផ្សព្វផ្សាយ និងសង្ខេបលទ្ធផលនៃការស្រាវជ្រាវ សម្រាប់ប្រើប្រាស់ និង
- បទប្បញ្ញត្តិ នីតិវិធី និងបទដ្ឋាននានា ដែលកំណត់ពីរបៀប ដែលជាតុផ្សំនៃប្រព័ន្ធនេះ ត្រូវបានប្រើប្រាស់ ជាផ្លូវការ និងក្រៅផ្លូវការ ក្នុងគោលបំណងដើម្បីបង្កឱ្យមាន**បរិយាកាសសមរម្យ ឬ ងាយស្រួលធ្វើការ**។

ទិន្នន័យ និងព័ត៌មាននៃការសិក្សា ត្រូវបានប្រមូល តាមរយៈ៖

- **ការពិនិត្យមើលឡើងវិញ**លើឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ របាយការណ៍វាយតម្លៃ និងរបាយការណ៍ផ្សេងៗទៀត ស្តីពីទិសដៅ និងយុទ្ធសាស្ត្រសេដ្ឋកិច្ច ព្រមទាំងវិស័យស្រាវជ្រាវនៅកម្ពុជា។
- **ការសម្ភាសន៍យកព័ត៌មានជាមួយបុគ្គលសំខាន់ៗ** ដែលជាអ្នករៀបចំគោលនយោបាយ/មន្ត្រីរាជការស៊ីវិល (ចំនួន ៦ រូប) ដៃគូអភិវឌ្ឍន៍ (ចំនួន ៥ រូប) ស្ថាប័នស្រាវជ្រាវ និងវិទ្យាស្ថានស្រាវជ្រាវ (ចំនួន ១៣) អង្គការមិនមែនរដ្ឋាភិបាល (ចំនួន ២) និងអ្នកស្រាវជ្រាវឯករាជ្យ (ចំនួន ៣ រូប)
- **ការពិនិត្យផ្ទៀងផ្ទាត់**លើការរកឃើញ ជាមួយជំនាញការ និងអ្នកពាក់ព័ន្ធសំខាន់ៗមួយចំនួន។

## ២. បញ្ហាប្រឈមនានា ក្នុងការអភិវឌ្ឍ និងអាទិភាពសម្រាប់គោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា

ឯកសារគោលនយោបាយសំខាន់ៗ ដែលកំណត់ពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាលកម្ពុជា រួមមាន យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ (RS៤)[2] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ[3] ដែលទើបនឹងទទួលបានការអនុម័តថ្មីៗ និងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (NSPPF) (២០១៦-២០២៥)[4] ។ ក្នុងន័យមួយទៀត រាល់ការស្រាវជ្រាវ និងការវិភាគនានា ដែលរៀបចំដោយដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត តែងតែប្រើឯកសារទាំងអស់នេះ ដើម្បីពិគ្រោះ និងពិពណ៌នាពីអាទិភាពនានា ដូចមានរៀបរាប់ក្នុងឯកសារទាំងនេះ។

តាមរយៈការសិក្សា និងពិនិត្យមើលលើពីឯកសារពិគ្រោះនានា វិស័យអាទិភាពមួយចំនួន ត្រូវបានស្នើឡើង សម្រាប់ការពិចារណា (សូមពិនិត្យមើលតារាងខាងក្រោម) ។ វិស័យអាទិភាពមួយចំនួន ក្នុងចំណោមវិស័យអាទិភាពដែលបានស្នើឡើងទាំងនេះ រាប់បញ្ចូលទាំងវិស័យដែលទាក់ទងនឹងយេនឌ័រ និងបរិយាប័ន្ន មានភាពស្របគ្នា ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា (CSDGs)។ វិស័យយេនឌ័រ និងបរិយាប័ន្ន ត្រូវបានមើលឃើញ ប្រកបដោយសុទិដ្ឋិនិយមថា យន្តការនានា ដែលមានតាមរយៈសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន អាចបង្កើតឱកាសយ៉ាងប្រសើរ សម្រាប់ការជំរុញឱ្យមានសមភាពយេនឌ័រ និងការពង្រឹងអំណាចសេដ្ឋកិច្ចរបស់ស្ត្រី នៅក្នុងតំបន់ និងនៅប្រទេសកម្ពុជា[5]។

---

[2] រាជរដ្ឋាភិបាលកម្ពុជា (២០១៨) យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤

[3] រាជរដ្ឋាភិបាលកម្ពុជា (២០១៩) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៩-២០២៣

[4] រាជរដ្ឋាភិបាលកម្ពុជា (២០១៧) ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (NSPPF) (២០១៦-២០២៥)

[5] ការប្រមើមើលទៅលើផលប៉ះពាល់យេនឌ័រ សម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ាន ទីក្រុងចាកាតា លេខាធិការដ្ឋានអាស៊ាន ខែ មិថុនា ឆ្នាំ ២០១៦

ការរកឃើញជារួម តាមរយៈឯកសារគោលនយោបាយដែលបានអាន និងពិនិត្យមើលឡើងវិញ សម្រាប់ការសិក្សានេះ ដែលផ្តល់ដោយក្រសួង ស្ថាប័ន និងលទ្ធផលស្រាវជ្រាវ ដែលផ្តល់ដោយអ្នកស្រាវជ្រាវជាច្រើន បង្ហាញថា ពួកគេបានទទួលស្គាល់ដូចគ្នា ពីភាពរីកចម្រើនដ៏គួរឱ្យកត់សម្គាល់ លើការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៅកម្ពុជា ប៉ុន្តែក៏នៅមានបញ្ហាប្រឈមនានាជាច្រើន និងការពង្រីកវិសាលភាពរបស់ខ្លួន ទាមទារឱ្យប្រទេសកម្ពុជា ត្រូវចំណាយពេលវេលាពី ៥ ទៅ ១០ ឆ្នាំ ទៅមុខទៀត ដើម្បីផ្លាស់ប្តូរមុខមាត់ប្រទេស ដោយត្រូវពឹងផ្អែកជាចម្បងទៅលើកត្តាខាងក្នុងស្រុក និងខាងក្រៅស្រុក ដូចជា ការធ្វើសមាហរណកម្មសេដ្ឋកិច្ច តួនាទីរបស់ប្រទេសចិន ជំនាញនិងនិយោជន៍ អភិបាលកិច្ច និងសេវាគាំពារសង្គម។

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ (RS៤) និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៩-២០២៣ (NSDP) បានដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រចំនួន ៤ សម្រាប់ប្រទេសកម្ពុជា នៅឆ្នាំ ២០២៣ រួមមាន ស្ថិរភាពនយោបាយនិងកំណើនសេដ្ឋកិច្ច និយោជន៍និងជំនាញ ការកាត់បន្ថយភាពក្រីក្រនិងភាពងាយរងគ្រោះ និងអភិបាលកិច្ចល្អ។ ដើម្បីជួយចូលរួមចំណែក ដល់ការសម្រេចបាននូវគោលដៅទាំង ៤ នេះ វិស័យជាយុទ្ធសាស្ត្រចំនួន ៤ ត្រូវបានដាក់ចេញ រួមមាន៖ ការអភិវឌ្ឍធនធានមនុស្ស ការធ្វើពិពិធកម្មសេដ្ឋកិច្ច (economic diversification) ការអភិវឌ្ឍវិស័យឯកជននិងនិយោជន៍ និងការអភិវឌ្ឍប្រកបដោយចីរភាព។ វិស័យដែលមានលក្ខណៈជាអន្តរវិស័យ ដូចជា យេនឌ័រ បរិយាប័ន្ន និងភាពងាយរងគ្រោះ ត្រូវបានដាក់បញ្ចូល នៅក្នុងគោលនយោបាយជាតិចម្បងៗ ដូចជា NSPPF ផែនការជាយុទ្ធសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រ របស់ក្រសួងអប់រំ យុវជន និងកីឡា (GMAP) ២០១៦-២០២០[6] ដែលមានសង្គតិភាពទៅនឹង ផែនការវិស័យអប់រំ (ESP) គោលនយោបាយយេនឌ័រ *DGTVET* ឆ្នាំ ២០១៦[7] ។ ដោយវាជាផ្នែកមួយ នៅក្នុងរបៀបវារៈរបស់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការងារអាទិភាពនានារបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ ត្រូវបានរៀបចំឱ្យមានសង្គតិភាពជាមួយនឹងបញ្ហាទាំងនេះផងដែរ។

កំណែទម្រង់អភិបាលកិច្ច និងស្ថាប័ន គឺជាចំណុចស្នូល សម្រាប់គោលដៅ និងវិស័យជាយុទ្ធសាស្ត្រ ដែលបានរៀបរាប់ខាងលើ។ កំណែទម្រង់អភិបាលកិច្ចសំខាន់ៗចំនួន ៣ រួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) វិមជ្ឈការ (វិមជ្ឈការ និងវិសហមជ្ឈការ) និងកំណែទម្រង់រដ្ឋបាលសាធារណៈ។ នាពេលថ្មីៗនេះ មានចំណុចមួយសំខាន់ទៀត ដែលជាចំណុចទី ៤ ត្រូវបានបន្ថែមពីលើចំណុចទាំង ៣ នេះ គឺ ការត្រួតពិនិត្យ និងវាយតម្លៃ (M&E)។ កត្តានេះ មិនត្រឹមតែសំដៅទៅលើកម្មវិធី ឬ គម្រោងតាមវិស័យប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅទៅក្នុងគោលនយោបាយកម្រិតម៉ាក្រូផងដែរ ហើយវាបង្ហាញពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួន តាមរយៈការរៀបចំបង្កើតទិន្នន័យ ការស្រាវជ្រាវ និងការវិភាគ លើការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេស។ រាជរដ្ឋាភិបាល ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) កំពុងរៀបចំបញ្ចប់ក្របខ័ណ្ឌស្តីពីការត្រួតពិនិត្យ និងវាយតម្លៃថ្មីមួយ ដើម្បីវាស់វែងពីវឌ្ឍនភាពរបស់ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ (RS៤) និងដើម្បីបំពេញបន្ថែមទៅលើប្រព័ន្ធតាមដាន និងវាយតម្លៃ ដែលកំពុងប្រើ

[6] ក្រសួងអប់រំ យុវជន និងកីឡា (២០១៥) ផែនការជាយុទ្ធសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រ នៅក្នុងវិស័យអប់រំ ២០១៦-២០២០ ការបកប្រែក្រៅផ្លូវការ រាជធានីភ្នំពេញ

[7] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ DGTVET (២០១៦) ផែនការសកម្មភាព និងគោលនយោបាយយេនឌ័រ រាជធានីភ្នំពេញ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (២០១៧) ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលស្ថិតិ ឆ្នាំ ២០១៥-២០១៦ ការិយាល័យ TVETMIS នាយកដ្ឋានព័ត៌មានទីផ្សារការងារ រាជធានីភ្នំពេញ

សម្រាប់ NSDP ។ អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត គឺជាអ្នកចូលរួមវិនិយោគយ៉ាងសំខាន់ ក្នុងការរៀបចំបង្កើត ប្រើប្រាស់ និង តាមដាននិងវាយតម្លៃទិន្នន័យ ទៅលើបញ្ហាយេនឌ័រ និងបញ្ហានានាទាក់ទងនឹងការគាំពារសង្គម ព្រមទាំងគោលនយោបាយ។

តាមរយៈការពិនិត្យមើលលើឯកសារគោលនយោបាយនានា យើងសុំស្នើឱ្យមានវិស័យគោលនយោបាយ/ បញ្ហាគោលនយោបាយចំនួន ២ ប្រភេទ ដែលអាចផ្តល់ឱកាស ឱ្យធ្វើការអនុវត្តសាកល្បងពីរបៀបក្នុងការពង្រឹងវិស័យស្រាវជ្រាវ ជាពិសេស ការផលិតនូវការស្រាវជ្រាវ ដែលអាចប្រើសម្រាប់គោលនយោបាយ។ វិស័យគោលនយោបាយទី ១ អាចមានតម្រូវការកាន់តែច្រើន ដើម្បីពង្រឹងសមត្ថភាព ក្នុងការរៀបចំបង្កើតទិន្នន័យ ការវិភាគ និងស្រាវជ្រាវ។ ការប្រាប់បញ្ចូលគ្នា ដូចការលើកឡើងនេះ គឺជារឿងមួយដ៏ល្អបំផុត និងអាចប្រើធ្វើជាបរិបទសម្រាប់ការពិភាក្សាទាក់ទងនឹងជាតុផ្សំ និងការអភិវឌ្ឍវិស័យស្រាវជ្រាវនៅកម្ពុជា។

| វិស័យអាទិភាពទី ១ | វិស័យអាទិភាពទី ២ |
|---|---|
| • ការងារ ជំនាញ និងទេសន្តរប្រវេសន៍ការងារ (migration)<br>• គោលនយោបាយការបរទេស ការវិនិយោគផ្ទាល់ពីបរទេស និងបម្រែបម្រួលឥទ្ធិពលរបស់មហាអំណាចនៅក្នុងតំបន់<br>• ការគាំពារសង្គម<br>• ភាពងាយរងគ្រោះនៅក្នុងទីក្រុង<br>• ការផ្តល់សេវាសាធារណៈ និងនវានុវត្ត (innovation)<br>• កសិកម្ម | • ការអប់រំ<br>• សុខាភិបាល<br>• វិស័យហិរញ្ញវត្ថុ និងបំណុលគ្រួសារ<br>• វិស័យសេវា<br>• សេដ្ឋកិច្ចឌីជីថល (Digital economy)<br>• ការលើកកម្ពស់សហគ្រាសខ្នាតតូច និងមធ្យម<br>• វិស័យយុត្តិធម៌ |

## ៣. វិស័យស្រាវជ្រាវនៅកម្ពុជា

លទ្ធផលស្រាវជ្រាវដែលបានបង្ហាញនៅក្នុងផ្នែកនេះ ឆ្លុះបញ្ចាំងពីការយល់ឃើញរបស់បុគ្គលសំខាន់ៗ ដែលបានចូលរួមក្នុងការសម្ភាសន៍សម្រាប់ការសិក្សានេះ ទៅតាមវិស័យ និងប្រធានបទក្នុងវិស័យស្រាវជ្រាវ ដែលរួមមាន ការអភិវឌ្ឍសេដ្ឋកិច្ច គោលនយោបាយការបរទេស អភិបាលកិច្ច វិមជ្ឈការ ការងារនិងជំនាញ យេនឌ័រ ការគាំពារសង្គម និងការចិញ្ចឹមជីវិតនៅតំបន់ជនបទ។

មានក្រុមមនុស្ស ៣ ក្រុម នៅក្នុងប្រព័ន្ធស្រាវជ្រាវ រួមមាន អ្នកប្រើលទ្ធផលដែលបានមកពីការស្រាវជ្រាវ អន្តរការី និងអ្នកសរសេរឯកសារស្រាវជ្រាវ។ អ្នករៀបចំគោលនយោបាយ (និងមន្ត្រីរាជការស៊ីវិល) គឺជាក្រុមអ្នកប្រើលទ្ធផលដែលបានមកពីការស្រាវជ្រាវដ៏សំខាន់។ តម្រូវការលទ្ធផលស្រាវជ្រាវ ដែលបានមកពីការស្រាវជ្រាវសម្រាប់ពួកគេ ត្រូវបានបែងចែកជា (i) តម្រូវការការស្រាវជ្រាវលើជំនាញឯកទេស សម្រាប់ការរៀបចំបង្កើតគោលនយោបាយ និង/ឬ បញ្ហាបច្ចេកទេសណាមួយជាក់លាក់ (ឧទាហរណ៍៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អំពើហិង្សាលើស្ត្រី) (ii) ទិន្នន័យពីការស្ទង់មតិ សម្រាប់ការរៀបចំបង្កើតគោលនយោបាយណាមួយជាក់លាក់ (ឧទាហរណ៍៖ ការធ្វើទំនើបកម្មកសិកម្ម ការគាំពារសង្គម) (iii) ការយល់ឃើញរបស់ប្រជាពលរដ្ឋ លើបញ្ហា

ណាមួយជាក់លាក់ (ឧទាហរណ៍៖ ប្រាក់ឈ្នួលអប្បបរមា) និង (iv) ទិន្នន័យពីការវាយតម្លៃលើផលប៉ះពាល់ (ឧទាហរណ៍៖ លទ្ធផលនៃការប្រើប្រាស់ថវិកា ក្នុងវិស័យមួយជាក់លាក់)។

តាមរយៈការសម្ភាសន៍ យើងឃើញមានក្រុមមនុស្ស ពីអ្នកប្រើលទ្ធផលដែលបានមកពីការស្រាវជ្រាវ ចំនួន ៣ ក្រុម រួមមាន ដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល សាធារណជន និងសាកលវិទ្យាល័យ។

ក្រៅពីជាអ្នកផ្តល់ជំនួយដ៏ធំ ក្នុងការសរសេរឯកសារស្រាវជ្រាវ (ចំណុចនេះនឹងនិយាយនៅពេលក្រោយ) ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ត្រូវការការស្រាវជ្រាវលើជំនាញឯកទេស និងទិន្នន័យពីការស្ទង់មតិ ដើម្បីប្រើសម្រាប់ការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៅក្នុងកម្មវិធី និងគម្រោងរបស់ពួកគេ។ គម្រោងស្រាវជ្រាវដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងរយៈពេល ៣០ ឆ្នាំ ចុងក្រោយនេះ គឺមានច្រើនសន្ធឹកសន្ធាប់ខ្លាំងណាស់ ប៉ុន្តែវាមិនសូវមានឥទ្ធិពលខ្លាំង ទៅលើគោលនយោបាយនោះទេ ដោយសារតែមាតិការបស់វា ត្រូវបានផ្តោតសំខាន់ទៅលើតែកម្មវិធី និងគម្រោងច្រើនជាង។ សាស្ត្រាចារ្យសាកលវិទ្យាល័យ អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ និងនិស្សិត ត្រូវការទិន្នន័យ ការវិភាគ និងការស្រាវជ្រាវ សម្រាប់ការបង្រៀន និងគម្រោងស្រាវជ្រាវ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវជាច្រើនបានបង្ហាញថា តម្រូវការទាំងនោះនៅតែមានកម្រិតតិចតួចនៅឡើយ។ សាធារណជនទូទៅ បានក្លាយជាក្រុមមនុស្សដ៏សំខាន់ ដែលមានតម្រូវការ និងប្រើការស្រាវជ្រាវ ដោយសារតែការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ប្រព័ន្ធផ្សព្វផ្សាយសង្គមនៅ កម្ពុជា (ជាពិសេស សង្គមហ្វេសប៊ុក) ហើយវេទិកាទាំងនេះក៏ត្រូវបានប្រើផងដែរ (មិនត្រឹមតែចំពោះ) ដើម្បី ផ្តល់ជាយោបល់ពីព្រឹត្តិការណ៍នយោបាយសំខាន់ៗ។

ចំពោះអ្នករៀបចំនយោបាយ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវការទិន្នន័យ ការវិភាគ និងការស្រាវជ្រាវ ភាគច្រើន ដើម្បីប្រើសម្រាប់បំពេញអាណត្តិ កម្មវិធី គោលនយោបាយខាងក្រៅ និងរបៀបវារៈសម្រាប់ការអភិវឌ្ឍន៍ ដូចជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា SDGs ។ ការប្រមូលទិន្នន័យបែងចែកតាមវិស័យ លើបញ្ហាសមភាពយេនឌ័រ និងបរិយាប័ន្នសង្គម (GESI) គឺមានការលំបាកខ្លាំងណាស់ (ឧទាហរណ៍៖ វាមានភាពខុសគ្នាខ្លាំងពេក រវាងគុណភាព និងទិន្នន័យបែងចែកតាមវិស័យ ដែលទទួលបាន នៅក្នុងវិស័យអប់រំ ឬ វិស័យសុខាភិបាល ធៀបនឹងវិស័យកសិកម្ម និងវិស័យយុត្តិធម៌)។ តម្រូវការទាំងនេះ កំពុងតែមានការកើនឡើងជាលំដាប់ ដោយទទួលនូវឥទ្ធិពលពីការបង្កើតភស្តុតាងតាមបែបថ្មី ដូចជា ការវិភាគពីការយល់ឃើញរបស់ប្រជាពលរដ្ឋ និងមតិយោបល់ពីប្រព័ន្ធផ្សព្វផ្សាយសង្គម (social media)។ តាមវិធីនេះ ប្រព័ន្ធផ្សព្វផ្សាយសង្គម (និងការវិភាគទិន្នន័យពីប្រព័ន្ធផ្សព្វផ្សាយសង្គម) អាចដើរតួយ៉ាងសំខាន់ ក្នុងការលើកជាសំណួរថ្មីៗ ដែលអ្នករៀបចំគោលនយោបាយ គួរតែយកចិត្តទុកដាក់ ឬ ត្រូវធ្វើការស្វែងយល់បន្ថែមទៀត[8]។

ទន្ទឹមនឹងការដែលមានថវិកាដ៏ច្រើនសន្ធឹកសន្ធាប់ សម្រាប់ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា ដែលទទួលបានពីដៃគូអភិវឌ្ឍន៍ ក៏មានការផ្តួចផ្តើមសម្រាប់ការស្រាវជ្រាវជាច្រើន ដែលរៀបចំឡើង ដោយរាជរដ្ឋាភិបាល តាមរយៈការប្រើប្រាស់ថវិកាជាតិផងដែរ។ ឧទាហរណ៍៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំធ្វើការស្ទង់មតិ និងការសិក្សាស្តីពីមុខរបរ ការងារ និងកម្លាំងពលកម្ម (labour) ការអប់រំមូលដ្ឋាន និងការប្រើប្រាស់ថវិកាជាតិសម្រាប់សេវាសាធារណៈ។ ទាំងអស់នេះ គឺជាសញ្ញាវិជ្ជមាន ដែលក្រសួង ស្ថាប័ន បានងាកមកសិក្សា

[8] វេទិកាបណ្តាញសង្គម ក៏អាចជាកន្លែង ដែលផ្តល់ព័ត៌មានក្លែងក្លាយ ដែលនាំឱ្យការយល់ច្រលំ និងមានអាកប្បកិរិយាបែបអវិជ្ជមាន ក្នុងឆ្លើយតបទៅនឹងភស្តុតាងផ្សេងៗដែលមានជាក់ស្តែង។

និងប្រើនូវលទ្ធផលស្រាវជ្រាវផ្សេងៗ មុនពេលរៀបចំបង្កើតគោលនយោបាយ ដែលកិច្ចការនេះវាត្រូវការពេលវេលាយូរ ដោយសារដំណើរការការងារនៅក្នុងក្រសួង ស្ថាប័នមានលក្ខណៈស្មុគស្មាញ ដែលនេះគឺជារបៀបធ្វើការងារ របស់រដ្ឋបាលសាធារណៈ។ កត្តានេះ វាជាផ្នែកមួយ បណ្តាលមកពីការមិនមានការទទួលស្គាល់ស្របគ្នា នៅក្នុងចំណោមក្រសួង ស្ថាប័នរដ្ឋដ៏ច្រើន ទៅលើសក្តានុពល និងតម្លៃនៃភស្តុតាង ដែលបានមកពីការស្រាវជ្រាវ សម្រាប់ការរៀបចំបង្កើតគោលនយោបាយ ព្រមទាំងបណ្តាលមកពីដំណើរការលទ្ធកម្មសាធារណៈ ដែលមានលក្ខណៈការិយាល័យធិបតេយ្យ និងការប្រើប្រាស់ពេលវេលាយូរ សម្រាប់កម្មវិធីសេវាសាធារណៈ (ផ្ទុយពីសេវាសាធារណៈខាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត)។

គម្លាតរវាងអ្នកប្រើលទ្ធផលដែលបានមកពីការស្រាវជ្រាវ (knowledge users) និងស្ថាប័ន/អ្នកធ្វើការសិក្សាស្រាវជ្រាវ(knowledge producers) ជាពិសេស រវាងអ្នករៀបចំគោលនយោបាយ និងមន្ត្រីរាជការស៊ីវិល ព្រមទាំងអ្នកសរសេរឯកសារស្រាវជ្រាវ ដែលត្រូវបានគេចាត់ទុកថា មិនស្ថិត "នៅក្នុងរង្វង់ [គោលនយោបាយ]"។ កត្តាប្រទាក់គ្នាទាំង ៣ នេះ អាចត្រូវបានពន្យល់ពីភាពប្រទាញប្រទុងគ្នានៅក្នុងគម្លាតទាំងនេះគឺ៖ (១) ការខ្វះការជឿទុកចិត្ត (២) ភាពទន់ខ្សោយក្នុងការប្រាស្រ័យទាក់ទង ដែលអាចនាំឱ្យមានការយល់ច្រឡំ និង (៣) ភាពទន់ខ្សោយ ឬ អវត្តមាននូវបទដ្ឋាន និងរបៀបបែបបទ ក្នុងការធ្វើការ និងការសហការជាមួយគ្នា។ កត្តាចន្លោះប្រហោងទាំងនេះ ចាប់មានតាំងពីដំណាក់កាលចាប់ផ្តើមនៃការស្រាវជ្រាវ ហើយវាអាចធ្វើឱ្យប៉ះពាល់ដល់ ភាពពាក់ព័ន្ធ គុណភាព និងការបកស្រាយនូវលទ្ធផល និងអនុសាសន៍របស់ការស្រាវជ្រាវ។

## ៤. ស្ថាប័ន/អ្នកធ្វើការសិក្សាស្រាវជ្រាវ

ផ្អែកតាមវិទ្យាស្ថានជាតិស្ថិតិ (NIS) មន្ទីរស្ថិតិ និងការិយាល័យនានានៅក្នុងមន្ទីរ យើងបានកំណត់ក្រុមអ្នកសរសេរឯកសារស្រាវជ្រាវចំនួន ៦ ក្រុមផ្សេងគ្នា ដែលពាក់ព័ន្ធនឹងបញ្ហាគោលនយោបាយ៖ (i) អង្គភាព[៩]/អង្គការ/ក្រុមស្រាវជ្រាវរបស់ក្រសួង ស្ថាប័ន (ii) ជំនាញការបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ (iii) ស្ថាប័នស្រាវជ្រាវ និងវិទ្យាស្ថានស្រាវជ្រាវ (iv) មជ្ឈមណ្ឌលស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យ (v) ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និង (vi) ក្រុមហ៊ុនទីប្រឹក្សា និងទីប្រឹក្សាឯកត្តជន។

មុននឹងឈានទៅដល់ការពិភាក្សាលម្អិតពីការរកឃើញជាក់លាក់ ចរិតលក្ខណៈនៃលទ្ធផលស្រាវជ្រាវបែបអន្តរវិស័យចំនួន ៣ នៅកម្ពុជា នឹងត្រូវបានលើកយកមករៀបរាប់ ដូចខាងក្រោមនេះ៖

១. ក្នុងរយៈពេលជាង ២០ ឆ្នាំ កន្លងមកនេះ មានគម្រោងស្រាវជ្រាវ ដែលមិនមានលក្ខណៈសម្របសម្រួលដ៏ច្រើនសន្ធឹកសន្ធាប់ ត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា និងនៅលើវិស័យគោលនយោបាយសំខាន់ៗ របស់ប្រទេសកម្ពុជា។ ទិន្នន័យ ការវិភាគ និងគម្រោងស្រាវជ្រាវដ៏ច្រើន ត្រូវបានរៀបចំឡើង ដោយមានការគាំទ្រ

[៩] ក្រសួងសំខាន់ៗមួយចំនួនតូច ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំបង្កើតក្រុមស្រាវជ្រាវផ្ទាល់ខ្លួន ដើម្បីឆ្លើយតបទៅតាម ការរៀបចំបង្កើតគោលនយោបាយជាក់លាក់ និងតម្រូវការក្នុងការត្រួតពិនិត្យ និងវាយតម្លៃ។ ប៉ុន្តែ តួនាទី និងមុខងារ របស់ក្រុមទាំងនោះ មានលក្ខណៈមិនផ្លូវការ និងផ្អែកតាមតែការចាំបាច់ប៉ុណ្ណោះ។

ពីដៃគូអភិវឌ្ឍន៍[10]។ ប៉ុន្តែ មិនមានអ្នកណាដឹងពីគម្រោងដ៏ច្រើនទាំងអស់នេះទេ[11]។ ជាពិសេស ចំណុចនេះ កើតឡើងជាក់ស្តែងពិតប្រាកដ ចំពោះបញ្ហា និងប្រធានបទនានា ដែលទាក់ទងនឹង សមភាពយេនឌ័រ និងបរិយាប័ន្នសង្គម (GESI) ។

២. និស្សិតកម្ពុជាវ័យក្មេងជាច្រើន បានទទួលអាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស ហើយបានត្រឡប់មកវិញ ជាមួយនឹងចំណេះដឹង និងជំនាញថ្មីៗ ដូចជា ខាងបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) ដែលអាចជួយគាំទ្រដល់ការអនុវត្ត និងផ្សព្វផ្សាយពីការស្រាវជ្រាវ។ ប៉ុន្តែ មិនមានអ្នកណាដឹង ថាតើសក្តានុពលចំពោះធនធាន និងចំណេះដឹងទាំងនោះ ត្រូវបានយកមកប្រើយ៉ាងដូចម្តេចនោះទេ។

៣. មានការកើនឡើង នូវក្រុមអ្នកជំនាញវិជ្ជាជីវៈ អ្នកប្រតិបត្តិ និងសហគ្រិន (រាប់បញ្ចូលទាំងសាកលវិទ្យាល័យឯកជនផងដែរ) ដែលកំពុងឱ្យតម្លៃលើការស្រាវជ្រាវ ហើយមានបំណងចង់ប្រើប្រាស់ការរកឃើញដែលបានមកពីការស្រាវជ្រាវ តាមរយៈការយកវាមកអនុវត្តជាក់ស្តែង។

ការសិក្សារបស់យើង បានផ្តោតសំខាន់ចំពោះវិទ្យាស្ថានស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ។ ក្រៅពីស្ថាប័នមួយចំនួនដែលមានដំណើរការល្អស្រាប់ ស្ថាប័នថ្មីៗមួយចំនួន ក៏ត្រូវបានបង្កើតឡើងផងដែរ ក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយនេះ ដែលភាគច្រើន ស្ថាប័នទាំងនេះត្រូវបានបង្កើតឡើង ដោយអ្នកស្រាវជ្រាវដែលមានកិត្តិស័ព្ទល្អ ព្រមទាំងមានបណ្តាញ និងទំនាក់ទំនងល្អជាមួយអង្គភាពរដ្ឋ។ ស្ថាប័នស្រាវជ្រាវមួយចំនួនតូច ក្នុងចំណោមស្ថាប័នដែលទើបថ្មីទាំងនេះ មានទំនាក់ទំនងទៅនឹងសាកលវិទ្យាល័យរដ្ឋ ឬសាកលវិទ្យាល័យឯកជន។ ស្ថាប័នស្រាវជ្រាវមួយចំនួនធំ ធ្វើការស្រាវជ្រាវគ្របដណ្តប់ទៅលើ ស្ទើរគ្រប់វិស័យគោលនយោបាយ (ឧទាហរណ៍៖ អភិបាលកិច្ច សេដ្ឋកិច្ច ការអប់រំ) ចំណែកឯ ស្ថាប័នស្រាវជ្រាវខ្លះទៀត ធ្វើការស្រាវជ្រាវផ្តោតសំខាន់ទៅលើបញ្ហាគោលនយោបាយជាក់លាក់ ដូចជា គោលនយោបាយការបរទេស ឬ មានលក្ខណៈតូចដូចការផ្តួចផ្តើម **ខ្សែក្រវាត់មួយ-ផ្លូវមួយ(BRI)**។ បេសកកម្ម និងគោលដៅរបស់ពួកគេ (មិនថាក្នុងទម្រង់ជាការសរសេរ ឬមិនបានសរសេរ) បានលើកឡើងពីការចូលរួមចំណែក តាមរយៈការប្រើប្រាស់ភស្តុតាង ដែលបានមកពីការស្រាវជ្រាវ សម្រាប់ការរៀបចំបង្កើតគោលនយោបាយ ការកសាងសមត្ថភាពលើការស្រាវជ្រាវ និង/ឬលើកកម្ពស់ការយល់ដឹងជាសាធារណៈលើបញ្ហាគោលនយោបាយសំខាន់ៗ។ ប៉ុន្តែ របៀបដែលពួកគេធ្វើប្រតិបត្តិការ និងគ្រប់គ្រងការងាររបស់ពួកគេ មានលក្ខណៈផ្សេងៗគ្នា គួរឱ្យកត់សម្គាល់។ តាមរយៈនេះ យើងបានសង្កេតឃើញចំណុចសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- វិទ្យាស្ថានស្រាវជ្រាវ/ស្ថាប័នស្រាវជ្រាវមួយចំនួនតូច មានការទាក់ទងយ៉ាងស្អិតរមួត នៅក្នុងរង្វង់នៃការរៀបចំបង្កើតគោលនយោបាយ (ពួកគេស្ថិតនៅខាងក្រៅរង្វង់ [គោលនយោបាយ])។ ការទាក់ទងនេះ អាចកើតមានឡើង ដោយសារកត្តា ២ សំខាន់ៗគឺ៖ (i) ការមានទំនាក់ទំនងផ្ទាល់ខ្លួនល្អ និងការជឿទុកចិត្ត ដែលនាយកប្រតិបត្តិ/ប្រធានក្រុមប្រឹក្សាភិបាល និង/ឬ អ្នកស្រាវជ្រាវជាន់ខ្ពស់ មានជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និង (ii) មានការគាំទ្រ ដែលទទួលបានពីដៃគូអភិវឌ្ឍន៍ ក្នុងការបង្កើតទំនាក់ទំនងនេះ។ ឬ និយាយម៉្យាងទៀតថា ទំនាក់ទំនងរវាងស្ថាប័នស្រាវជ្រាវ និងអ្នករៀបចំគោលនយោបាយ

[10] ការប្រមូលទិន្នន័យធំៗមួយចំនួនតូច ត្រូវបានគេរំពឹងទុកថា នឹងមានក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀត រួមមាន ការធ្វើជំរឿនប្រជាជនថ្នាក់ជាតិ ជំរឿនកសិកម្ម ជំរឿនប្រជាសាស្ត្រ និងគ្រួសារតាមផ្ទះ (CDHS) និងការស្ទង់មតិកម្លាំងការងារ បើអាចទៅរួច។

[11] ប៉ុន្តែ មិនមានទិន្នន័យជាក់លាក់ ស្តីពីចំនួនគម្រោងទាំងនោះពិតប្រាកនោះទេ។

មានការពឹងផ្អែកយ៉ាងខ្លាំង ទៅលើភាពចាំបាច់ និងទៅលើទំនាក់ទំនងផ្ទាល់ខ្លួន របស់បុគ្គលសំខាន់ៗ ដែលបានលើកឡើងខាងលើ។

- គម្រោងស្រាវជ្រាវភាគច្រើន អនុវត្តតាមដំណើរការស្រាវជ្រាវស្តង់ដារមួយ ដែលចាប់ផ្តើមពីដំណាក់កាលនៃការរៀបចំដំបង រហូតដល់ដំណាក់កាលនៃការផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយ។ បញ្ហាប្រឈមមួយចំនួន ដែលកើតមាននៅក្នុងដំណើរការនេះ គឺថា តម្រូវការក្នុងការរៀបចំបង្កើតសំណួរស្រាវជ្រាវ នៅក្នុងដំណាក់កាលចាប់ផ្តើមដំបង ដែលវាមានសារៈសំខាន់ចំពោះអ្នករៀបចំគោលនយោបាយ។ ចំពោះដំណាក់កាលអនុវត្ត វាមានការលំបាកក្នុងទទួលបាននូវទិន្នន័យ និងបណ្តុំទិន្នន័យ ដូចបានរៀបរាប់ខាងលើ ព្រោះវានៅតែមានភាពរាយប៉ាយ។ រីឯ ក្នុងដំណាក់កាលផ្សព្វផ្សាយវិញ បញ្ហាប្រឈមគឺថា ពិបាកធ្វើឱ្យព័ត៌មាននោះទៅដល់អ្នកប្រើប្រាស់ពិតប្រាកដ។ ចំណែកឯ ដំណាក់កាលបោះពុម្ពផ្សាយវិញ បញ្ហាប្រឈមគឺខ្វះដំណើរការធានានូវគុណភាពឱ្យអាចជឿទុកចិត្តបាន ជាពិសេសនៅក្នុងការពិនិត្យមើលឡើងវិញដោយអ្នកជំនាញ ។ នៅដំណាក់កាលចុងក្រោយនេះ គេសង្កេតឃើញថា គម្រោងស្រាវជ្រាវ អាចមានដំណើរការពិនិត្យមើលឡើងវិញ ដោយសហសេវិកយ៉ាងហ្មត់ចត់ លុះត្រាតែគម្រោងស្រាវជ្រាវនោះ ជាគម្រោងដែលស្ថិតនៅក្នុងគម្រោងថ្នាក់តំបន់ និង/ឬ មានទំនាក់ទំនងទៅនឹងសាកលវិទ្យាល័យនៅក្រៅប្រទេស។ បញ្ហាប្រឈមសំខាន់មួយទៀតនោះគឺ ទាក់ទងនឹងការជ្រើសរើសបណ្តុះបណ្តាល និងរក្សាទុកអ្នកស្រាវជ្រាវ ដែលមានសមត្ថភាពនៅក្នុងស្ថាប័ន។ ចំពោះអ្នកស្រាវជ្រាវដែលមានសមត្ថភាព នៅពេលដែលពួកគេទទួលបានបទពិសោធន៍ច្រើនគ្រប់គ្រាន់ហើយ ពួកគេនឹងជ្រើសរើសទៅធ្វើការ ជាទីប្រឹក្សាឯករាជ្យ ព្រោះពួកគេអាចទទួលបានប្រាក់កម្រៃច្រើន។
- លទ្ធផលនៃការស្រាវជ្រាវ រួមមាន ផ្នែកមតិយោបល់ ឯកសារស្រាវជ្រាវ អត្ថបទទិនានុប្បវត្តិ និងឯកសារគោលនយោបាយ។ ការផ្សព្វផ្សាយពីលទ្ធផលនៃការស្រាវជ្រាវ ជាទូទៅ ត្រូវបានរៀបចំឡើង តាមរយៈសិក្ខាសាលា ដែលពេលខ្លះ ទាមទារឱ្យមាន សេចក្តីសង្ខេបគោលនយោបាយ ឬ ការផ្សព្វផ្សាយពីការរកឃើញ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងប្រព័ន្ធសារព័ត៌មាន។ បញ្ហាចម្បងមួយ ដែលជាញឹកញាប់មិនត្រូវបានគេយកចិត្តទុកដាក់នោះគឺ ការងាយទទួលបាន និងគុណភាព ចំពោះឯកសារស្រាវជ្រាវជាភាសាខ្មែរ ដែលភាគច្រើន ត្រូវបានគេគិតពីតម្រូវការនេះ បន្ទាប់ពីភាសាអង់គ្លេសត្រូវបានរៀបចំរួច។
- ប្រព័ន្ធ ដើម្បីវាយតម្លៃ ក្នុងការប្រើប្រាស់ និងផលប៉ះពាល់នៃការប្រើប្រាស់ឯកសារស្រាវជ្រាវ គឺនៅមានភាពទន់ខ្សោយខ្លាំងក្នុងស្ថាប័ន ដែលភាគច្រើនពឹងផ្អែកទាំងស្រុង ទៅលើការសង្កេតជាឯកតោភាគី និងការធានាអះអាងដោយខ្លួនឯង។ គេអាចនិយាយបានថា ការវាយតម្លៃលើការប្រើប្រាស់ និងផលប៉ះពាល់នៃការប្រើប្រាស់ឯកសារស្រាវជ្រាវ អាចកើតមានបាន លុះត្រាតែឯកសារនោះត្រូវបានរៀបចំដោយបុគ្គល ដែលត្រូវបានគេចាត់ទុកថា ស្ថិតនៅក្នុង "រង្វង់គោលនយោបាយ" រួមមាន ក្រុមស្រាវជ្រាវផ្ទាល់របស់ស្ថាប័នរដ្ឋ ជំនាញការបច្ចេកទេស (រាប់បញ្ចូលទាំងអ្នកផ្តល់ជំនួយ និងទីប្រឹក្សាឯកត្តជន ផងដែរ) ដែលជំនាញរបស់ពួកគេ ត្រូវបានស្នើសុំដោយផ្ទាល់ពីរាជរដ្ឋាភិបាល។ ដោយសារនៅតែមានការពឹងផ្អែកទាំងស្រុងទៅលើជំនាញការខាងក្រៅ ហេតុនេះដើម្បីអាចសម្រេចលទ្ធផលរំពឹងទុកពីការស្រាវជ្រាវបាន ជំនាញការនោះត្រូវតែធ្វើការយ៉ាងជិតស្និទ្ធ ជាមួយក្រុមស្រាវជ្រាវផ្ទៃក្នុង (ហើយដោយសង្ឃឹមថា នឹងអាចជួយកសាងសមត្ថភាពផងដែរ)។

- មានទស្សនៈមួយ ចំពោះចម្ងល់អំពីការប្រើប្រាស់ និងផលប៉ះពាល់នៃការប្រើប្រាស់ឯកសារស្រាវជ្រាវនេះគឺថា សម្រាប់គម្រោងស្រាវជ្រាវដែលពាក់ព័ន្ធនឹងគោលនយោបាយ វាមិនចាំបាច់ទាល់តែយកទៅប្រើប្រាស់តែម្ខាងនោះទេ (ពោលគឺ សំដៅចំពោះកម្រិតអ្នករៀបចំគោលនយោបាយ) ប៉ុន្តែវាគួរតែពិចារណាពីការយកទៅប្រើនៅម្ខាងទៀតផងដែរ (ពោលគឺ សំដៅចំពោះស្ថាប័នផ្សេងទៀត ដែលមានលក្ខណៈស្រដៀងគ្នា និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងសាធារណជន)។ ក្រៅពីការផ្តោតតែទៅលើការប្រើប្រាស់ឯកសារស្រាវជ្រាវពីថ្នាក់លើ វាគួរតែមានការយកចិត្តទុកដាក់ពីគ្រប់ជ្រុង ទាំងផ្នែកចំហៀង និងផ្នែកខាងក្រោម ជាពិសេសការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល ទៅលើមតិសាធារណជន (ភាគច្រើន ត្រូវបានបញ្ចេញ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម) ដើម្បីតម្រែតម្រង់ទិសចំពោះតម្រូវការក្នុងការស្រាវជ្រាវរបស់ខ្លួន និងអាទិភាពនានា ក្នុងការរៀបចំគោលនយោបាយ។

## ៥. អនុសាសន៍សម្រាប់កម្មវិធី

តាមរយៈលទ្ធផលនៃការស្រាវជ្រាវ យើងសូមផ្តល់យោបល់ ដូចខាងក្រោម៖

- **ចំពោះកម្រិតយុទ្ធសាស្ត្រ** មានចំណុចចំនួន ២ ដែលគួរយកមកធ្វើការពិចារណា។ ទីមួយ កម្មវិធីគួរតែមានភាពច្បាស់លាស់ ចំពោះគោលបំណងរបស់ខ្លួន ក្នុងការជួយគាំទ្រទៅលើវិស័យស្រាវជ្រាវ ដូចជា (i) មានគោលបំណងធ្វើឱ្យមានឥទ្ធិពលលើការរៀបចំគោលនយោបាយ (ii) ដើម្បីកសាងសមត្ថភាពដល់ក្រុមជាក់លាក់ ដែលជាអ្នកសរសេរឯកសារស្រាវជ្រាវ និង (iii) ដើម្បីផ្សព្វផ្សាយពីបញ្ហាជាក់លាក់ដល់សាធារណជនទូទៅ ឱ្យបានកាន់តែទូលាយ។ គោលបំណងទាំងនេះ គឺគ្រាន់តែជាការបំពេញបន្ថែមប៉ុណ្ណោះ។ ដើម្បីអាចដឹងថាគោលបំណងណាមួយមានភាពសំខាន់ខ្លាំង ឬតិចនោះ វាអាស្រ័យទៅនឹងការរៀបចំបង្កើតកម្មវិធី។ ទីពីរ កត្តានិរន្តរភាព គួរតែត្រូវបានយកចិត្តទុកដាក់ ចាប់តាំងពីដំបូងនៃដំណាក់កាលរៀបចំបង្កើតកម្មវិធី ព្រោះវានឹងជួយតម្រែតម្រង់ទិស ក្នុងការរៀបចំបង្កើតកម្មវិធីផងដែរ។ យើងសូមផ្តល់យោបល់ជាក់ស្តែងមួយថា ដើម្បីធានានូវនិរន្តរភាព គឺត្រូវចំណាយពេលដែលមានក្នុងរយៈពេល ៣ ឆ្នាំនៃកម្មវិធីនេះ (មិនមែនធ្វើតែនៅចុងបញ្ចប់នៃកម្មវិធីនោះទេ) ធ្វើការស្រាវជ្រាវពី "កត្តាដែលបង្ហាញពីឥទ្ធិពលជាវិជ្ជមាន" និង "គោលការណ៍រៀនសូត្របណ្តើរ ធ្វើបណ្តើរ ចង់ក្រងបណ្តើរ" ទៅលើរបៀប ដែលសមត្ថភាព របស់អ្នកសរសេរឯកសារស្រាវជ្រាវ នៅក្នុងប្រព័ន្ធស្រាវជ្រាវ ត្រូវបានអភិវឌ្ឍ ដើម្បីឱ្យពួកគេអាចបង្កើតជាគំនិតថ្មីៗ និងផ្តល់ជាយោបល់ សម្រាប់ការផ្តួចផ្តើមផ្សេងៗទៀត។

- ចំពោះ**កម្រិតគ្រប់គ្រង និងកម្រិតប្រតិបត្តិការ** កម្មវិធីគួរតែផ្តោតលើ "ការបំពេញបន្ថែមលើចំណុចខ្វះចន្លោះ" ជាជាងការវិនិយោគទៅលើការបង្កើតអ្វីដែលថ្មី លើកលែងតែចំណុចថ្មីនោះ មានគុណតម្លៃជាយុទ្ធសាស្ត្រខ្លាំង។ ត្រង់ចំណុចនេះ ចង់បញ្ជាក់សង្កត់ធ្ងន់ខ្លាំងទៅលើ តួនាទីរបស់កម្មវិធី ក្នុងនាមជា "លេខាធិការ" និង "អ្នកសម្របសម្រួល" ដែលមិនមែនជាអ្នកអនុវត្ត។ ពាក់ព័ន្ធនឹងការរៀបចំសំណួរ និងមាតិការបស់កម្មវិធី យើងសូមផ្តល់អនុសាសន៍ថា គួរតែរៀបចំឱ្យមានលក្ខណៈងាយយល់ និងច្បាស់លាស់ ចំពោះគោលបំណង និងលទ្ធផល ដែលត្រូវធ្វើឱ្យសម្រេច ព្រមទាំងកំណត់ពីអ្នកទទួលខុសត្រូវ

ទៅលើអ្វី ដែលត្រូវធ្វើ។ ក្រៅពីនេះ គួរតែរក្សាភាពសាមញ្ញ និងភាពងាយស្រួលយល់ ដើម្បីអាចធានាថា អ្នកពាក់ព័ន្ធសំខាន់នានា មានការយល់ដឹងរួមគ្នាពីបេសកកម្ម ព្រមទាំងអាចកសាងការជឿទុកចិត្តពីអ្នកពាក់ព័ន្ធទាំងនោះ។

- ទាក់ទងនឹង**ការជំរុញឱ្យមានឥទ្ធិពលទៅលើគោលនយោបាយ និងការកសាងភាពជាដៃគូ** យុទ្ធសាស្ត្រនៃការបំពេញបន្ថែមលើចំណុចខ្វះចន្លោះ អាចធ្វើឡើង ក្នុងទម្រង់ជា (i) រៀបចំបង្កើត និងជួយគាំទ្រដល់គណៈកម្មាធិការចម្រុះ រវាងក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិល (ដូចជា គណៈកម្មាធិការផ្តល់យោបល់ផ្នែកបច្ចេកទេស) (ii) ជំរុញឱ្យមានការចូលរួម ពីអ្នកពាក់ព័ន្ធសំខាន់ៗ ដែលមានបទពិសោធន៍ផ្សេងៗគ្នា ដើម្បីជួយគាំទ្រដល់ការរៀបចំទិសដៅ និងប្រធានបទនៃការស្រាវជ្រាវ អនុវត្ត និងផ្តល់យោបល់លើលទ្ធផលនៃការស្រាវជ្រាវ (iii) លើកកម្ពស់កិច្ចសហការ ជាមួយស្ថាប័នស្រាវជ្រាវក្នុងស្រុក និង (iv) រៀបចំបង្កើតឱ្យមានទំនាក់ទំនង រវាងស្ថាប័នស្រាវជ្រាវក្នុងស្រុក ជាមួយបណ្តាញស្រាវជ្រាវ និងសាកលវិទ្យាល័យនានា នៅក្នុងតំបន់។

- ចំពោះ**ការកសាងសមត្ថភាព** ការបំពេញបន្ថែមលើចំណុចខ្វះចន្លោះ អាចធ្វើឡើង ក្នុងទម្រង់ជា (i) ធ្វើការសម្របសម្រួល ដល់ការទទួលបាន និងប្រើប្រាស់ទិន្នន័យដែលមានស្រាប់ សម្រាប់គោលបំណងស្រាវជ្រាវ ឱ្យប្រកបដោយប្រសិទ្ធភាព (ii) ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស/ការបណ្តុះបណ្តាលរួមគ្នា ទៅលើរបៀបក្នុងការរៀបចំសរសេរឯកសារស្រាវជ្រាវ សម្រាប់ផ្សព្វផ្សាយក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម (iii) ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ទៅលើរបៀបរៀបចំ និងកែលម្អ នូវដំណើរការនៃការធានាគុណភាព និងការពិនិត្យមើលឡើងវិញពីសហសេវិក (ដោយធ្វើការសហការ ជាមួយបណ្តាញស្រាវជ្រាវនានា នៅក្នុងតំបន់ ស្ថាប័នស្រាវជ្រាវ និងសាកលវិទ្យាល័យនៅក្រៅប្រទេស) (iv) រៀបចំកសាងសមត្ថភាព ដល់ក្រសួង ស្ថាប័ន ឱ្យយល់ពីសារៈសំខាន់ និងពីរបៀបប្រើប្រាស់ទិន្នន័យ ដែលបែងចែកតាមភេទ ដើម្បីឱ្យអាចមានការពិចារណា សមភាពយេនឌ័រ និងបរិយាប័ន្នសង្គម (GESI) កាន់តែល្អប្រសើរ សម្រាប់ការរៀបចំបង្កើតគោលនយោបាយ (v) រៀបចំបង្កើតឱ្យមានទំនាក់ទំនង រវាងវិទ្យាស្ថានស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវនានា ជាមួយសាកលវិទ្យាល័យ និងសមាគមអតីតនិស្សិតនានា ដើម្បីចែករំលែកព័ត៌មាន ពីឱកាសកសាងសមត្ថភាព និងឱកាសការងារពាក់ព័ន្ធនឹងការស្រាវជ្រាវ ព្រមទាំង (vi) ជំរុញលើកទឹកចិត្ត ឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត ទៅលើតម្រូវការឯកសារស្រាវជ្រាវជាភាសាខ្មែរ។

គម្រោងពន្លកចំណេះទទួលបានការឧបត្ថម្ភគាំទ្រពី ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី។ ពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា គឺជាគម្រោងរយៈពេលបីឆ្នាំ (២០១៩-២០២២) ដែលផ្តួចផ្តើមឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវដើម្បីលើកកម្ពស់ការស្រាវជ្រាវប្រកបដោយគុណភាព ដែលអាចប្រើប្រាស់ជាទិន្នន័យគាំទ្រដល់ការវិភាគ និងការពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា។

អំណះអំណាង៖

ការស្រាវជ្រាវនេះទទួលបានការឧបត្ថម្ភគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈក្រសួងការបរទេស និងពាណិជ្ជកម្ម។ ទស្សនៈដែលលើកឡើងនៅក្នុងការស្រាវជ្រាវនេះគឺជាទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ ពោលគឺមិនបានឆ្លុះបញ្ចាំងអំពីទស្សនៈ និងការយល់ឃើញរបស់រដ្ឋាភិបាលអូស្ត្រាលី ឬអង្គការមូលនិធិអាស៊ីឡើយ។

សូមទាក់ទងមកយើងខ្ញុំ៖

www.policypulse.org/ponlok-chomnes

ponlokchomnes@asiafoundation.org

+៨៥៥ ២៣ ២១០ ៤៣១